# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៣ សរណន

## សារាចរណែនាំ
## របស់រាជរដ្ឋាភិបាលកម្ពុជា

យោងតាមមាត្រា ៥២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុវត្តតាមស្មារតីណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ការិយាល័យសន្តិសុខថ្នាក់កណ្តាល អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាន នគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានដាក់ចេញនូវសារលិខិតអំពាវនាវ និងបទបញ្ជាជាបន្តបន្ទាប់ ដើម្បីធានាការថែរក្សាស្ថិរភាព សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ហើយនិងដើម្បីរក្សានិរន្តរភាពរបស់រដ្ឋ ដែលជាការត្រូវធានាដោយរាជរដ្ឋាភិបាលសំដៅរក្សាប្រក្រតីភាពដំណើរការរដ្ឋបាលសាធារណៈ ក៏ដូចវិស័យសេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោមៈ

១- មន្ត្រីរាជការស៊ីវិលក្នុងក្របខណ្ឌមុខងារសាធារណៈ គ្រប់លំដាប់ថ្នាក់ត្រូវតែចូលមកបម្រើការងារជាធម្មតានៅតាមក្រសួង ស្ថាប័ន សាលាខេត្ត-ក្រុង មន្ទីរ អង្គភាពរបស់ខ្លួន បន្ទាប់ពីបានបញ្ចប់ការសុំច្បាប់ឈប់សម្រាកការងារទៅបំពេញបេសកកម្ម ក្នុងឱកាសយុទ្ធនាការឃោសនាបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រអាណត្តិទី ៣នេះ។ ប្រធានក្រសួង ស្ថាប័ន អង្គភាព សាលាខេត្ត-ក្រុង និងមន្ទីរជុំវិញខេត្ត-ក្រុង ត្រូវគ្រប់គ្រងបញ្ជីវត្តមាន ឱ្យបានជាប់ជាប្រចាំនិងម៉ត់ចត់។

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មាន ភារកិច្ចក្នុងការគ្រប់គ្រងបញ្ជីវត្តមានរបស់មន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ន និងខេត្ត-ក្រុង រួចរាយការណ៍ជូនរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងករណីអវត្តមានគ្មានមូលហេតុ គ្រប់ក្រសួង ស្ថាប័ន និងសាលាខេត្ត ក្រុង ត្រូវចាត់វិធានការណ៍អនុវត្តជាបន្ទាន់តាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លក្ខន្តិកៈដោយឡែកនៃមន្ត្រីរាជការស៊ីវិលនិងបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងមន្ត្រីរាជការស៊ីវិល ជាពិសេសកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលកំពុងស្ថិតនៅជាធរមាននៅឡើយ។

២- យោធិន កងរាជអាវុធហត្ថជាតិនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិទាំងអស់ ត្រូវមកបំពេញ ការងារជាប្រក្រតីជាកំហិត ដោយនាំមកវិញនូវរាល់មធ្យោបាយ សម្ភារៈ គ្រឿងបំពាក់ អាវុធគ្រាប់រំសេវ ដែលខ្លួនបានយកទៅក្រៅកងឯកភាព។ រីឯមេបញ្ជាការគ្រប់កងឯកភាព នាយកគ្រប់ស្ថាប័ននៃកង-យោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និងកងនគរបាលជាតិ ត្រូវធ្វើការត្រួតពិនិត្យ និងរាយការណ៍អំពីលទ្ធផលនៃការប្រមូលកម្លាំង និងគ្រឿងបំពាក់ឱ្យបានជាប់ជាប្រចាំ និងម៉ឺងម៉ាត់។ យោធិន កងរាជអាវុធហត្ថជាតិ និងកងនគរបាលជាតិ ដែលមិនគោរពតាមការណែនាំនេះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងបទប្បញ្ញត្តិ វិន័យរបស់កងនគរបាលជាតិ។

៣- ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំបង្កើនការថែរក្សា និងធានាទប់ស្កាត់ការបាត់បង់សម្ភារៈការិយាល័យ និងសម្ភារៈនានារបស់រដ្ឋ ដើម្បីធានាឱ្យដំណើរការជាប្រក្រតីនៃរដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

៤- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអប់រំពលរដ្ឋ កុំឱ្យជឿពាក្យឃោសនា ញុះញង់ អុជអាលគ្មានការពិត ដើម្បីធានាការពារឱ្យបាននូវសន្តិសុខ សុវត្ថិភាព ស្ថិរភាពសង្គម សណ្ដាប់ធ្នាប់សាធារណៈ និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ។

ទទួលបានសារាចរនេះ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង ស្ថាប័ន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអភិបាលគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តតាមខ្លឹមសារខាងលើឱ្យបានសម្រេចលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

លេខ: ១៥២ ច.ល.ម.ស
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមជូន:
ឯកឧត្តមអនុរដ្ឋលេខាធិការ ឯកឧត្តមអគ្គនាយក
ឯកឧត្តមអគ្គាធិការ លោកប្រធាននាយកដ្ឋាន
ដើម្បីជូនជ្រាប និងអនុវត្ត
ភ្នំពេញ ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០០៣

**រដ្ឋលេខាធិការ**

**ពេជ្រ ប៊ុនធិន**

**<u>ចម្លងជូន</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ–កាលប្បវត្តិ